# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៧១ សសរ

## សេចក្តីសម្រេច
ស្តីពី
ការកែសំរួលសមាសភាពក្រុមការងារបច្ចេកទេសចំរុះ
រាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្ម មាត្រា ៤ មាត្រា ១០ និងមាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចំរុះរាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១:** ត្រូវបានតែងតាំង និងកែសំរួលសមាសភាពក្រុមការងារបច្ចេកទេសចំរុះរាជរដ្ឋាភិបាល ប្រទេសម្ចាស់ជំនួយ លើវិស័យមីន ដូចខាងក្រោម :

១. ឯកឧត្តម **យ៉េង ម៉ារី** អគ្គលេខាធិការរងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ជាសមាជិកក្រុមការងារបច្ចេកទេសចំរុះ ជំនួសឯកឧត្តម ខឹម សោភ័ណ

www.pheakdeylaw.com

២. ឯកឧត្តម ហេង រតនា អគ្គនាយករង មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដែលជាសមាជិកក្រុមការងារបច្ចេកទេសចំរុះ មកជា *អ្នកសង្កេតការណ៍* វិញ

ប្រការ ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងសាមីខ្លួនដែលមាននាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល :*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*- ដូចប្រការ ២*

*- ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com